# ក្រឹត្យ-ច្បាប់

ស្តីពី

# ក្រឹត្យ-ច្បាប់

# បទល្មើសមានលក្ខណៈយោធា និងទណ្ឌកម្ម

## ក្រុមប្រឹក្សារដ្ឋ

បានឃើញរដ្ឋធម្មនុញ្ញ សាធារណៈរដ្ឋប្រមានិតកម្ពុជា

ដើម្បីការពារសន្តិសុខ ការពារប្រទេស ការពារកម្លាំងប្រយុទ្ធ របស់កងកម្លាំងប្រដាប់អាវុធប្រជាជន បដិវត្តកម្ពុជា ពង្រឹងវិន័យរបស់កងទ័ព និង ការពារនិត្យានុកូលភាព។

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារ ប្រទេស និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ព្រមផង។

## សំរេច

**មាត្រា ១-** គោលការណ៍បង្ក្រាបបទល្មើស។

គ្រប់អំពើល្មើស ដែលធ្វើអោយប៉ះពាល់ដល់កម្លាំងប្រយុទ្ធរបស់កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តកម្ពុជា និង ដល់បទបញ្ជានៃបរិចារកិច្ចយោធា ត្រូវរកអោយឃើញទាន់ពេលវេលា និង ផ្តន្ទាទោសតាមសមធម៌។

អំពើញុះញង់ ជំរុញជនច្រើនរូប អោយប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ត្រូវផ្តន្ទាទោសជាទម្ងន់។ អំពើដែលបណ្តាលអោយការខូចខាតធ្ងន់ធ្ងរ ឬ ធ្វើអោយប៉ះពាល់ជាខ្លាំង ដល់ការបំពេញភារកិច្ចរបស់អង្គភាពទ័ព ក៏ត្រូវផ្តន្ទាទោសជាទម្ងន់ដែរ។ ជនណាដែលបានបង្ហាញដោយស្មោះត្រង់ នូវសេចក្តីស្តាយក្រោយអំពីកំហុសរបស់ខ្លួន ហើយបានបង្កើតស្នាដៃណាមួយ ដើម្បីលុបលាងកំហុសនោះ អាចត្រូវបានសន្តោសទោស ឬ លើកលែងទេស។

**មាត្រ ២-** ការប្រឆាំងនឹងបញ្ជារបស់ថ្នaកលើ ។

យោធាណា ដែលប្រឆាំងជាសាធារណ៌ និងបញ្ជាថ្នាក់លើ ទាក់ខឹងនឹងករណីយកិច្ចយោធាសំខាន់ៗ ឬ មិនព្រមអនុវត្តបញ្ជានេះ ឬប្រព្រឹត្តដោយកើត នឹងទៅដោយផ្ទុយនឹងបញ្ជានេះ ត្រូវផ្តន្ទាទោសដាក់ក ៦ខែ ទៅ ៣ឆ្នាំ។

បើការប្រឆាំងនឹងបញ្ជា ធ្វើឡើងក្នុងពេលប្រយុទ្ធ ឬក៏អូសទាញជនច្រើនរូបនៅពេលជាមួយគ្នាអោយប្រឆាំងនឹងបញ្ជានោះ បណ្តាលអោយមានផលអាក្រក់ជាទម្ងន់ ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ១០ឆ្នាំ។ បើផលអាក្រក់មានលក្ខណៈធ្ងន់ធ្ងរជាពិសេសជនប្រព្រឹត្តបទល្មើសអាចត្រូវ ផ្តន្ទាទោសដាក់គុករហូតដល់ ២០ឆ្នាំ ឬ ដាក់គុកអស់មួយជីវិត ឬ ប្រហារជីវិត។

**មាត្រា ៣-** ការចុះចូលជាមួយខ្មាំង។

យោធាណាចុះចូលជាមួយខ្មាំង ត្រូវផ្តន្ទាទោសដាក់គុកពី ២ឆ្នាំ ទៅ ៥ឆ្នាំ។ បើមានការញុះញង់ ឬ ជំរុញជនច្រើនរូប ឱ្យចូលរួមប្រព្រឹត្តបទល្មើស នេះនៅពេលជាមួយគ្នា ឬ បើមានយកទាំងអាវុធ និងឯកសារសំខាន់ៗ ទៅជាមួយផង ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទេសដាក់គុករហូតដល់ ១០ឆ្នាំ។

ប្រសិនបើ អំពើប្រព្រឹត្តិនាំមកនូវផលអាក្រក់ធ្ងន់ធ្ងរជាពិសស ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទទោសដាក់គុករហូតដល់ ២០ ឆ្នាំ ឬ ដាក់គុកអស់មួយជីវិត ឬ ប្រហារជីវិត។

**មាត្រា ៤**- ការលួច ការលក់ ការទិញ ការជួយលក់គ្រឿងអាវុធ បរិក្ខារ សំលៀកបំពាក់ ឬ ប្រដាប់ ប្រដាមានតម្លៃច្រើនផ្សេងៗ ទៀត របស់កងទ័ព។

ជនណា លួច លក់ ទិញ ជួយលាក់គ្រឿងអវុធ បរិក្ខា សំលៀកបំពាក់ ប្រដាប់ប្រដាមានតម្លៃច្រើនផ្សេងទៀតរបស់កងទ័ព ត្រូវផ្តន្ទាទោសដាក់គុក ពី ១ឆ្នាំ ទៅ ៥ ឆ្នាំ។ ក្នុងករណីធ្ងន់ធ្ងរ ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសរហូតដល់ ១០ឆ្នាំ។

ម៉្យាងទៀត ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់រៀល ដែលនឹងកំណត់ទៅតាមលក្ខណៈ និង កំរិតនៃការខូចខាត បណ្តាលមកពីអំពើល្មើស។

**មាត្រា ៥**- ការគំរាមកំហែងភ្នាក់ងាររដ្ឋការ។

យោធាណា ដែលអាងលើមុខងាររបស់ខ្លួន អំណាចរបស់ខ្លួន ឬ អាងលើកម្លាំងគ្នាច្រើនប្រដាប់អាវុធ .. ដើម្បីគំរាមកំហែងអ្នករដ្ឋការណាមួយ ដែលកំពុងបំពេញភារកិច្ច បង្ខំអោយជននោះ បោះបង់ករណីយកិច្ចរបស់ខ្លួន ឬ ឲ្យប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចដែលជននោះត្រូវធ្វើ ត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ ៣ ឆ្នាំ។ បើអំពើប្រព្រឹត្តិនាំមកនូវផលអាក្រក់ធ្ងន់ធ្ងរ ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ១០ឆ្នាំ។

**មាត្រា ៦**- ការឃោសនាបំផ្លិចបំផ្លាញ ដើម្បីបំបែកបំបាក់កងទ័ព។

ជនណា ធ្វើការឃោសនាបំផ្លិចបំផ្លាញ ប្រឆាំងនឹងនយោបាយជាក់ស្តែងរបស់បដិវត្តន៍ ដើម្បីធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តកងទ័ព ដល់សាមគ្គីភាពនៃកងទ័ព ឬ ដើម្បីធ្វើឱ្យមានការបែកបាក់ រវាងកងទ័ព និងប្រជាជរវាងកងទ័ព និងផ្នែកនានា ត្រូវផ្តន្ទាទោសដាក់គុកពី ៦ខែ ទៅ ៣ឆ្នាំ។

**មាត្រា ៧**- ការវាយ និងការធ្វើឲ្យមានរបួស។

ក្នុងការទាក់ទងរវាងអ្នកបញ្ជា និងអ្នកទទួលបញ្ជាយោធណា ដែលប្រព្រឹត្តអំពើហឹង្សា ធ្វើឲ្យប៉ះពាល់ដល់រូបកាយរបស់កម្មាភិបាលថ្នាក់បញ្ជា ឬកម្មាភិបាលថ្នាក់បញ្ជាណាដែលវាយដំ ឬ ធ្វើបាបអ្នកនៅក្រោមបង្គាប់របស់ខ្លួន ត្រូវផ្តន្ទាទោសដាក់គុក ៦ ខែ ទោ ៣ឆ្នាំ។ បើអំពើប្រព្រឹត្តិ បណ្តាលឱ្យមានរបួសធ្ងន់ ឬ បណ្តាលឲ្យស្លាប់ ជនប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោស ពីបទវាយដំ និងធ្វើឲ្យគេមានរបួសដោយចេតនា ឬពីបទធ្វើមនុស្សឃាត។

ក្នុងករណីខាងក្រោយនេះ ការផ្តន្ទាទោស ត្រូវអនុវត្តតាមប្រការ ៧ នៃក្រឹត្យ-ច្បាប់ លេខ ០២ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០។

**មាត្រា ៨**- ការធ្វើអោយបែកការសម្ងាត់ និងការធ្វើអោយបាត់ឯក សារសម្ងាត់។

យោធាណា ដែលផ្សាយការសម្ងាត់យោធាដល់អ្នកដទៃ ដែលជាជនគ្មានការទទួលខុសត្រូវក្នុងរឿងសម្ងាត់នោះ ឬ យោធាណាធ្វើអោយបាត់ឯកសារសម្ងាត់ដោយការធ្វេសប្រហែស ត្រូវផ្តន្ទាទោសដាក់គុក ពី៦ ខែ ទៅ ៣ ឆ្នាំ។

**មាត្រា ៩**- ការខ្វះស្មារតីទទួលខុសត្រូវ និង ការមិនយកចិត្តទុកដាក់ក្នុងការងាររបស់ខ្លួន បណ្តាលអោយមានផលអាក្រក់ធ្ងន់ធ្ងរ។

យោធាណា ខ្វះស្មារតីទទួលខុសត្រូវ ឬមិនយកចិត្តទុកដាក់នឹងការងារ របស់ខ្លួន បណ្តាលអោយមានការខូចខាតធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ ៣ឆ្នាំ។ បើការខូចខាតនោះ មានលក្ខណៈធ្ងន់ធ្ងរពិសេស ជនប្រព្រឹត្តបទល្មើសអាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ១០ឆ្នាំ។

**មាត្រា ១០**- ការគេចវេះពីវិចារកិច្ចយោធា។

យោធាណា ក្នុងគោលបំណងគេចវេះពីបរិចារកិច្ចយោធាហើយ ដែលត្រូវបានអប់រំជាច្រើនលើកនៅតែមានរត់ចោលជួរ ឬ ធ្វើអោយខ្លួនឯងមានរបួស ឬ មានជម្ងឺបណ្តាលអោយបាត់សម្បទាក្នុងការប្រយុទ្ធ និងក្នុងពលកម្ម ឬ ប្រើឧបាយកលទុច្ចរិតផ្សេងៗទៀត ដើម្បីគេចវេះពិចារកិច្ចយោធា ត្រូវផ្តន្ទាទោសដាក់គុក ពី ៦ ខែ ទៅ ៣ឆ្នាំ។ ក្នុងករណីធ្ងន់ធ្ងរ ដូចជា ការជំរុញជនច្រើនរូបអោយរត់ចោលជួរ ការរត់ចោលជួរដោយយកជាមួយ នូវគ្រឿងអាវុធ បរិក្ខារសំខាន់ៗ របស់កងទ័ព ឬ ការប្រព្រឹត្តិបទល្មើលព្រហ្មទណ្ឌផ្សេងៗ ទៀត ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្តទោសដាក់គុករហូតដល់ ៥ឆ្នាំ។

**មាត្រា ១១**- បទល្មើសផ្សេងៗ ទៀត។

យោធាណា ប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌទាំងឡាយ ដែលមានចែងក្នុងក្រឹត្យ-ច្បាប់ លេខ ០២ ក.ច ចុះថ្ងៃទី ១៥ ឧសភា ឆ្នាំ១៩៨០ ត្រូវផ្តន្ទាទោស តាមទណ្ឌកម្ម ដែលមានកំណត់ក្នុងក្រឹត្យ-ច្បាប់ លេខ ០២ ក.ច ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៩៨០ នេះ ។

**មាត្រា ១២**- ក្រឹត្យ-ច្បាប់នេះ ត្រូវអនុវត្តទៅលើបទល្មើស ទាំងឡាយ ដែលបានកើតឡើងតាំងពីថ្ងៃ ៧ ខែមករា ឆ្នាំ១៩៧៩ ហើយដែលពុំទាន់បានដាក់ជំនុំជំរះ នៅឡើយ ។

មាត្រា ១៣- រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលអនុវត្តក្រឹត្យ-ច្បាប់នេះ តាមភារកិច្ច រៀងៗ ខ្លួន។

បានទទួលអនុវត្ត

ភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ១៩៨១

ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

**ហេង សំរិន**

បានទទួលអនុវត្ត

ជា ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ចាន់ ស៊ី**